# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

# ស្តីពី

# កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ

# ឆ្នាំ ២០១១

# រាជរដ្ឋាភិបាលកម្ពុជា

# និង

# រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីទំនាក់ទំនងជាមិត្តភាពដែលមានកន្លងមករវាងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងព្រះរាជាណាចក្រកម្ពុជា ក្នុងបំណងពង្រឹង និងរឹតទំនាក់ទំនងជាមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងស្មារតីភាពជាដៃគូ កិច្ចព្រមព្រៀងនេះ បង្កើតជាមូលដ្ឋានគ្រឹះនៃការថែរក្សាទំនាក់ទំនង ក្នុងគោលបំណងដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា យោងកំណត់ហេតុកិច្ចចរចាឆ្នាំ២០១១ រវាងរដ្ឋាភិបាលទាំងពីរនៅទីក្រុងបោន (Bonn) ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១១ និងកំណត់ទូត លេខ១៥៣/១១ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការសន្យាផ្តល់ហិរញ្ញប្បទាន

បានព្រមព្រៀងគ្នាដូចតទៅ៖

## មាត្រា ១

(១) រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់នឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា ឱ្យទទួលបានពី "សាជីវកម្មឥណទាននីតិសម្បទា៖ (Kreditanstalt für Wiederaufbau (KfW) " នូវការផ្តល់វិភាគទានហិរញ្ញវត្ថុ ជាទឹកប្រាក់សរុប ១៩.០០០.០០០ អឺរ៉ូ (ដប់ប្រាំបួនលានអឺរ៉ូ) សម្រាប់គម្រោងដូចខាងក្រោម៖

១- កម្មវិធីគាំពារសុខភាព ដំណាក់កាលទី៣ (Programme on Social Health Protection III) មានទឹកប្រាក់ដល់ត្រឹម ៤.០០០.០០០ អឺរ៉ូ (បួនលានអឺរ៉ូ)

២- កម្មវិធីរៀបចំដែនដី និងគោលនយោបាយដីធ្លី (Programme on Land Policy and Land Management) មានទឹកប្រាក់ដល់ត្រឹម ៣.០០០.០០០ អឺរ៉ូ (បីលានអឺរ៉ូ)

៣- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ ដំណាក់កាលទី៣ (Rural Infrastructure Programme III) មានទឹកប្រាក់ដល់ត្រឹម ៤.០០០.០០០ អឺរ៉ូ (បួនលានអឺរ៉ូ) ។

៤- ការជួសជុលហេដ្ឋារចនាសម្ព័ន្ធជនបទដែលខូចខាតដោយសារទឹកជំនន់ (Flood Repair Measures for Rural Infrastructures) មានទឹកប្រាក់ដល់ត្រឹម ៨.០០០.០០០ អឺរ៉ូ (ប្រាំបីលានអឺរ៉ូ) ។

ប្រសិនបើការសិក្សាត្រូវបានរកឃើញថា គម្រោងទាំងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជំរុញការអនុវត្ត ។

(២) គម្រោងដែលបានចែងដូចក្នុងកថាខ័ណ្ឌទី (១) ខាងលើ អាចនឹងត្រូវជំនួសដោយគម្រោងផ្សេងៗទៀត ប្រសិនបើ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា មានការឯកភាពគ្នា ។

(៣) កិច្ចព្រមព្រៀងនេះនឹងត្រូវអនុវត្តផងដែរនៅថ្ងៃក្រោយ បើរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ផ្តល់លទ្ធភាពឱ្យ រាជរដ្ឋាភិបាលកម្ពុជា ទទួលបានវិភាគទានហិរញ្ញវត្ថុពី KfW សម្រាប់ត្រៀមរៀបចំគម្រោង ដែលចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ សម្រាប់ចូលរួមចាត់វិធានការចាំបាច់ដើម្បីអនុវត្ត និងគាំទ្រគម្រោង ដែលចែងក្នុងកថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ២

(១) ការប្រើប្រាស់ចំនួនទឹកប្រាក់ដែលបានចែងក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះ និងល័ក្ខខ័ណ្ឌផ្តល់ជូន ក៏ដូចជានីតិវិធី សម្រាប់ផ្តល់កិច្ចសន្យា នឹងត្រូវគ្រប់គ្រងដោយកិច្ចសន្យានានាដែលចុះហត្ថលេខារវាង KfW និងអ្នកទទួលវិភាគទានហិរញ្ញវត្ថុ ដែលជាកម្មវត្ថុស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានា របស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

(២) ការប្តេជ្ញាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលមានចំនួនដូចបានបញ្ជាក់ក្នុងមាត្រា ១ (១) នៃកិច្ចព្រមព្រៀងនេះនឹងអស់សុពលភាព បើកិច្ចព្រមព្រៀងហិរញ្ញប្បទានដែលពាក់ព័ន្ធ មិនបានចុះហត្ថលេខាក្នុងរយៈពេល ៨ឆ្នាំ ក្រោយឆ្នាំនៃការសន្យាបានធ្វើឡើង ។ ទឹកប្រាក់នៃការប្តេជ្ញានេះមានសុពលភាពដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ។

(៣) រាជរដ្ឋាភិបាលកម្ពុជា ដែលមិនមែនជាអ្នកទទួលវិភាគទានហិរញ្ញវត្ថុនេះដោយផ្ទាល់ ត្រូវធានាលើការសងប្រាក់ទាន់ពេលកំណត់ទៅអោយ KfW វិញ ផ្អែកតាមកិច្ចសន្យាហិរញ្ញប្បទាននានា ដែលនឹងត្រូវបានចុះហត្ថលេខាស្របតាមកថាខ័ណ្ឌ (១) ខាងលើ ។

## មាត្រា ៣

រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលបន្ទុកក្នុងការបង់ពន្ធអាករ និង ថ្លៃសេវាសាធារណៈដទៃផ្សេងទៀត ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំនួសឱ្យ KfW ពាក់ព័ន្ធនឹងការសម្រេច និងការអនុវត្តកិច្ចសន្យានានាដែលចែងក្នុងមាត្រា ២ (១) នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

រាជរដ្ឋាភិបាលកម្ពុជាត្រូវអនុញ្ញាតឱ្យអ្នកដំណើរ និងអ្នកផ្គត់ផ្គង់ ជ្រើសរើសសហគ្រាសដឹកជញ្ជូនដោយសេរី សម្រាប់ការដឹកជញ្ជូនមនុស្ស និងទំនិញ តាមសមុទ្រ និងតាមអាកាស ដែលស្តែងចេញពីការផ្តល់វិភាគទានហិរញ្ញវត្ថុខាងលើ ដោយជៀសវាងពីការដាក់វិធានការណាមួយដែលអាចរារាំងការចូលរួម ឬ ធ្វើអោយលំបាកដល់ការចូលរួមដោយស្មើភាពគ្នារបស់សហគ្រាសដឹកជញ្ជូនដែលមានទីតាំងចុះកិច្ចនៅក្នុង សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងផ្តល់ការអនុញ្ញាតចាំបាច់សម្រាប់ការចូលរួមរបស់សហគ្រាសទាំងនោះ ។

## មាត្រា ៥

(១) ទឹកប្រាក់ហិរញ្ញប្បទានឥតសំណង និងវិភាគទានហិរញ្ញវត្ថុនៃគម្រោង ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ (Fund for Regional Economic Development) ដែលមានចែងក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០១០ រវាង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុឆ្នាំ ២០០៩ ចំនួន ៦.០០០.០០០ អឺរ៉ូ ( ប្រាំមួយលានអឺរ៉ូ ) ត្រូវបានគ្រោងនឹងផ្ទេរទៅប្រើប្រាស់សម្រាប់គាំទ្រគម្រោង “ កម្មវិធីគោលនយោបាយ ដីធ្លី និង រៀបចំដែនដី (Programme on Land Policy and Land Management)” ដែលបានចែងក្នុងមាត្រា ១ (១) ២ ខាងលើ ប្រសិនបើការសិក្សាត្រូវរកឃើញថា គម្រោងនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជម្រុញការអនុវត្ត ។

(២) រាល់ល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០១០ រវាង រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុឆ្នាំ២០០៩ នឹងត្រូវអនុវត្តសម្រាប់គម្រោងនេះ ។

# មាត្រា ៦

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី 9. August 2012 មាន ២ ច្បាប់ដើម ចម្លងជាបីភាសាគឺ ភាសាខ្មែរ អាល្លឺម៉ង់ និង អង់គ្លេស អត្ថបទទាំង ៣ ភាសានេះមានតំលៃដូចគ្នា ។ ក្នុងករណីការបកប្រែមិនស្របមតិគ្នារវាងអត្ថបទ ភាសាអាល្លឺម៉ង់ និង ខ្មែរ នោះអត្ថបទភាសាអង់គ្លេសនឹងត្រូវទុកជាបានការ ។

**តំណាង**
**រាជរដ្ឋាភិបាលនៃកម្ពុជា**

Keat Chhon

**តំណាងរដ្ឋាភិបាលនៃ**
**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**